01069579

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 02 / 2015
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
E1/256

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ពុធ ទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

**សវនាការលើអង្គសេចក្តី - ថ្ងៃ ២៣៧**

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង **Matthew McCARTHY**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ាង, លោក Matthew McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicolas KOUMJIAN, កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK, លោក Travis FARR, លោក Vincent de Wilde d'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក |

| |
|---|
| ហុង គឹមសួន, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ម៉ុច សុវណ្ណារី, លោកស្រី Martine JACQUIN |
| សាក្សី/ដើមបណ្តឹង៖ លោក កែវ ច័ន្ទតារ៉ា (2-TCW-964), លោក សយ សែន (2-TCCP-271) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ,លោកស្រី សួ សុទ្ធារី |
| ផ្សេងៗ៖ កញ្ញា ស្រី ណាក់, កញ្ញា សុក សុភ័គមណីកា, លោក មៀច សុវណ្ណា, កញ្ញា ពេជ ចរិយា, កញ្ញា តូច គន់នារី, កញ្ញា Sara ERJAVEC |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៣ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៧ | បញ្ចប់ម៉ោង៖ ១០.៣៣ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣១ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៣ | បញ្ចប់ម៉ោង៖ ១៥.០៣ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | **០៤ ម៉ោង និង ៣០ នាទី** |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៣ | ០៩.០៥ |
| ការស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការរបស់ជនជាប់ចោទ នួន ជា | មេធាវីការពារក្តី នួន ជា | ០៩.០៥ | ០៩.០៦ |
| ការបន្តតាំងសំណួរទៅកាន់សាក្សី កែវ ច័ន្ទតារ៉ា (2-TCW-964) | អង្គជំនុំជម្រះ<br><br>មេធាវីការពារក្តី នួនជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៨<br>០៩.៣៧<br>០៩.៣១<br>០៩.៤៨ | ០៩.៣០<br>០៩.៤០<br>០៩.៤៨<br>១០.៥១ |
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន (2-TCCP-271) | អង្គជំនុំជម្រះ<br>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា | ១០.៥៤<br>១១.០៦<br>១៤.១៣ | ១០.៥៨<br>១៤.១២<br>១៦.០២ |

| | | | |
|---|---|---|---|
| ការស្នើសុំចូលមើលឯកសារដែលបាន ដាក់ចូលឃ្លាំងផ្ទុកឯកសាររួម(interface) | មេធាវីការពារក្ដី ខៀវ សំផន អង្គជំនុំជម្រះ | ១១.០០ ១៣.៣១ | ១១.០១ ១៣.៣៣ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធី បន្ទាប់មកក្រឡាបញ្ជីបានរាយការណ៍ថាគ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែលោក Arthur VERCKEN និងជនជាប់ចោទ នួន ជា។ នួនជា ចូលរួមសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។

**ការស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការរបស់ នួន ជា**

អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ក្នុងការលះបង់សិទ្ធចូលរួមដោយផ្ទាល់ពីបន្ទប់សវនាការ និងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការបន្តតាំងសំណួរទៅកាន់សាក្សីកែវ ច័ន្ទតារ៉ា (2-TCW-964)**

អង្គជំនុំជម្រះបានសួរសំណួរមួយចំនួនបន្ថែមទៅសាក្សី។ បន្ទាប់មក មេធាវីការពារក្ដី នួន ជា បានធ្វើការតាំងសំណួរបន្តដោយស្នើសុំឲ្យមានការបង្ហាញនូវរូបថតទៅកាន់សាក្សី និងស្នើឲ្យសាក្សីបញ្ជាក់ពីអត្តសញ្ញាណបុគ្គលមួយចំនួននៅក្នុងរូបថតនោះ ឯកសារនេះកត់សម្គាល់ខាងក្រោមដោយភ្ជាប់ជាមួយកំណត់ហេតុនេះ និងមិនមាននៅក្នុងសំណុំរឿងទេ។ មេធាវីការពារក្ដី ខៀវ សំផន បានបន្តតាំងសំណួរទៅសាក្សី ។

**ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី សាយ សែន (2-TCCP-271)**

អង្គជំនុំជម្រះបានតាំងសំណួរមួយចំនួនទៅដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងអត្តសញ្ញាណរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងបានប្រាប់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ បន្ទាប់មក មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញា បានធ្វើការតាំងសំណួរបន្ត។

**ការស្នើសុំចូលមើលឯកសារដែលបានដាក់ចូលឃ្លាំងផ្ទុកឯកសាររួម**

មេធាវីការពារក្ដីខៀវសំផន បានស្នើឲ្យអង្គជំនុំជម្រះអនុញ្ញាតិឲ្យខ្លួនអាចចូលមើលឯកសារដែលនឹងត្រូវប្រើប្រាស់នៅក្នុងសវនាការដោយសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះ បានរំលឹកទៅភាគីទាំងអស់ឲ្យអនុវត្តតាមនីតិវិធីដែលបានកំណត់នៅក្នុងឯកសារ E319/7 ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| លេខ E3 | លេខ កសចស | ចំណងជើង | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5153 | | 00172042-00172045<br>00205087-00205091<br>00205087-00205091 | Written Record of Interview of KEO Chăndara | P | | 00205089<br>00205090 | 00205094 |
| E3/5846 | D366/7.1.305 | N/A<br>N/A<br>00012448-00012470 | DK Media Report entitled "Nouvelles diffusées de Phnom Penh par La Voix du KD", DK Embassy in Peking, No. 44; article entitled "Internal News" | P | N/A | N/A | 00012468<br>00012469 |
| E3/5847 | | 01068466-01068466<br><br>01068465-01068465 | Photographic array | P | | | |
| E3/5848 | D22/1370.2 | | Annex 2: Former prisoner of Kraing Ta Chang | P | 00527797 | 00527800 | 00314056 |
| E3/2063 | | 00290925-00290926<br>00068182-00068183<br>00810641-00810642 | Kus Commune, Tram Kok District, Takeo Province, Takea Province, Site No. 210901 and 210902 | P | 00290925 | 0068182 | 00810641 |
| E3/2063 | | 00096763-00096778<br>00095660-00095672<br>00836731-00810642 | DC-Cam Report entitled "Mapping Project, 1997" | P | | 00095660 | |
| E3/5129 | | 00163501-00163502<br>00223483-00223485<br>00178108-00178109 | Written Record of Interview of SAY Sen | P | 00163502 | 00223484 | 00178109 |
| E3/5214 | | 00223055-00223070<br>00225500-00225513<br>00702886-00702902 | [Corrected 1] Written Record of Interview of SÂY Sen | P | 00223063<br>00223069 | 00225507<br>00225508<br>00225512 | 00702900<br>00702894 |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួន ខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យអង្គភាពសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការនៅក្រោមសាលសវនាការ (០៩.០៧)។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ (១៦.០៤)។

<u>កាលវេលាសវនាការបន្ត</u>

សវនាការនឹងបន្តទៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលវុឌ្ឍី** **Matthew McCARTHY**